## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍
# កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកុម្ភៈ ឆ្នាំ២០២២
# ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី**

១)- **ថ្ងៃ ខែ ឆ្នាំ៖** នាព្រឹកថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២២។

២)- **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣)- ប្រធាន និងសមាសភាពចូលរួម ៖

- ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ឯកឧត្តម លោកជំទាវ ជាអនុប្រធាន អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការរង ទីប្រឹក្សា ជំនួយការ ប្រធាននាយកដ្ឋាន នៅក្នុងសាលប្រជុំ "ខ" ។
- លោក អ្នកស្រី អ្នកនាងកញ្ញា អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុការិយាល័យ ព្រមទាំងមន្ត្រីនៃ អ.ជ.ប.ជ.អ ចូលរួមតាមបណ្តាញវីដេអូ កម្មវិធី Zoom។

៤)- របៀបវារៈ ៖

- បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ ២០២២ ដោយឯកឧត្តម **ឈឹម ឃិនដារ៉េត**។
- បទបង្ហាញស្តីពីបច្ចុប្បន្នភាពនៃការពង្រឹងស្ថាប័នការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយ ឯកឧត្តម **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។
- មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី
- កិច្ចការផ្សេងៗ។

៥)- លទ្ធផល ៖

១). **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

ក- សកម្មភាពការងារដែលសម្រេចបាន ៖

- កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២ ស្តីពីវឌ្ឍនភាពនៃការអនុវត្ត PrEP នៅកម្ពុជា គឺផ្តល់សេវាបង្ការ ថែទាំ និងព្យាបាលយ៉ាងទូលំទូលាយ តាមរយៈការឆ្លើយតបពហុវិស័យ។
- បានប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ពិនិត្យវឌ្ឍនភាពការងារ និងដាក់ទិសដៅ។
- បានរៀបចំធាតុចូលសម្រាប់របាយការណ៍របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សស្តីពីសិទ្ធិមនុស្សក្នុងបរិបទជំងឺHIV/AIDS។
- បានរៀបចំទិន្នន័យផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២២-២០២៤ (PIP) ជូនក្រសួងផែនការ។
- បានកំពុងប្រមូលទិន្នន័យសម្រាប់រៀបចំរបាយការណ៍ស្តីពីមេរោគអេដស៍សកលឆ្នាំ២០២១ (Global AIDS Monitoring 2021)។
- រៀបចំផ្តល់ធាតុចូលលើសេចក្តីព្រាងចុងក្រោយឯកសារគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ។
- បានបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការត្រួតពិនិត្យតាមដានការអនុវត្តសេចក្តីណែនាំ ស.ជ.ណ២១៣។
- បានចូលរួម "ទិវាសប្តាហ៍គាំពារសង្គម"ជាមួយប្រធានបទ" ឆ្ពោះទៅការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមសម្រាប់គ្រប់គ្នា"។
- បានចូលរួមយុទ្ធនាការទិវាស្រោមអនាម័យអន្តរជាតិឆ្នាំ២០២២ នៅខេត្តកំពង់ព្រះសីហនុ។
- បានរៀបចំយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងទិវានៃក្តីស្រឡាញ់។
- បានប្រជុំក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ. លើកទី២ ឆ្នាំ២០២២។
- បានតាមដាន ឯកសារសុំដំឡើងកាំប្រាក់ជូនថ្នាក់ដឹកនាំ និងមន្ត្រី ចំនួន៣៣រូប មន្ត្រីចំនួន១៨ ដែលបានស្នើឡើងកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្រសួងសុខាភិបាល។
- បានដំណើរការថវិកាជាតិតាមនីតិវិធីហិរញ្ញវត្ថុ សំណើសុំថវិកា ទូទាត់ថវិកា និងដកថវិកាបានចំនួន៧លើក។
- ការអនុវត្តសកម្មភាពក្នុងគម្រោងមូលនិធិសកល ឆ្នាំ២០២២នេះ គឺប្រព្រឹត្តទៅសម្រេចតាមផែនការ។

## ខ- បញ្ហាប្រឈម ៖

- ចំពោះជនគន្លឹះដែលមានបំណងមកទទួល PreP មានការពិបាកក្នុងការមកទទួល PreP ដោយសារការខ្វះថវិកាសម្រាប់ធ្វើដំណើរ។
- ស្ថានភាពជំងឺកូវីដ១៩ នៅតែបន្តផលប៉ះពាល់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

## គ- ទិសដៅអនុវត្តបន្ត ៖

- បន្តសហការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- បន្តប្រមូលទិន្នន័យរៀបចំរបាយការណ៍ស្តីពីមេរោគអេដស៍សកលឆ្នាំ២០២១ (Global AIDS Monitoring 2021) (Global AIDS Monitoring 2021)
- រៀបចំផ្តល់ធាតុចូលលើសេចក្តីព្រាងចុងក្រោយឯកសារគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ តាមសំណើរបស់ក្រសួងកិច្ចការនារី។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៣។

២). **បទបង្ហាញស្តីពីបច្ចុប្បន្នភាពនៃការពង្រឹងស្ថាប័នការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយឯកឧត្តម ធា ផលា ៖**

- បញ្ចប់វិសមភាព បញ្ចប់អេដស៍ បញ្ចប់ជំងឺឆ្លងរាតត្បាតសកល ដោយយកប្រជាពលរដ្ឋជាធំ ក្នុងន័យប្រឹងប្រែងស្តាប់ពីតម្រូវការពលរដ្ឋ ហើយរៀបចំសេវាស្របតាមតម្រូវការពលរដ្ឋ ពិសេសពលរដ្ឋងាយរងគ្រោះ។
- ផ្តល់អាទិភាពដល់តំបន់ភូមិសាស្ត្រសម្រាប់អន្តរាគមន៍ នៃគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍ ( Fast Track City) មាន រាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ។
- ត្រួតពិនិត្យតាមដានការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ នៅក្នុងគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍រាជធានីភ្នំពេញ និងខេត្តទាំង៣។
- ការចូលរួមរបស់ *ក្រុមប្រជាជនគន្លឹះ និងអ្នករស់នៅជាមួយមេរោគអេដស៍* (KP/PLHIV) ៨០%លើការបង្ការ ៣០%លើការថែទាំព្យាបាល និង៦០%លើបរិយាកាសគាំទ្រ។
- *អភិក្រម* ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ដោយឈរលើសសរស្តម្ភទាំង៣ គឺទី១)- *ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ការ* (Leadership and ownership) ទី២)- *ភាពជាដៃគូ* (Partnership) ទី៣)- *ការវិនិយោគ* (Investment) ដោយដាក់មនុស្ស និងសហគមន៍ នៅចំណុចកណ្តាលនៃការឆ្លើយតបនឹងជំងឺអេដស៍។
- ក្របខណ្ឌរៀបចំការតាមដានជំងឺអេដស៍ ដោយអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSPV) និងសេចក្តីជូនដំណឹងលេខ២១៣។
- *ការអនុវត្តយុទ្ធសាស្ត្រ ដើម្បីពន្លឿនការសម្រេចបានគោលដៅ*

៣). **លោកជំទាវ ស៊ឹម ខេងខាំ**

បានរំឭកស្តីពីទិវាអន្តរជាតិនារី៨មីនា ខួបលើកទី ១១១ ក្រោមប្រធានបទ "*សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត*" ដែលនឹងប្រារព្ធនាថ្ងៃទី០៤ខែមីនា ឆ្នាំ២០២២ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤). **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

ឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

- ត្រូវបន្តទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន រាជធានី/ខេត្ត ដោយណែនាំពីសកម្មភាពដែលបានអនុវត្ត ហើយធ្វើរបាយការណ៍មកឱ្យអ.ជ.ប.ជ.អ ឱ្យទាន់ពេលវេលា ដើម្បីទទួលបានការលើកទឹកចិត្ត និងប័ណ្ណសរសើរពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- មានតួលេខ៩៥-១០ (ថ្មី) ថែមមួយទៀត ដូច្នេះយើងត្រូវដឹងទាំងអស់គ្នា ដោយសម្រាយពន្យល់ឱ្យបានច្បាស់លាស់ រួចចែកជូនដល់ប្រតិបត្តិករទាំងអស់ឱ្យបានយល់។
- ខិតខំធ្វើតេស្ត ដោយរកឱ្យឃើញអ្នកដែលបាត់ចំនួន១២,000ករណី ដោយសហការជាមួយ NCHADS, UNAIDS និងស្ថាប័នពាក់ព័ន្ធទាំងអស់។
- ត្រូវបន្តពិក្សាឱ្យបានច្បាស់លាស់ជាមួយ UNAIDS និងNCHADS លើចំនុច *៩៥ទី២* ដោយឃើញថា តួលេខនេះមិនត្រឹមត្រូវ តួលេខដែលពិតប្រាកដ គឺអ្នកដែលមកទទួលសេវាប្រចាំថ្ងៃ។
- ចំពោះ*ក្រុមប្រជាជនគន្លឹះ* (KP) ដែលមានការពិបាកក្នុងការមកទទួល PreP ដោយសារខ្វះថវិកាសម្រាប់ធ្វើដំណើរ យើងត្រូវណែនាំពួកគាត់ឱ្យបានយល់ពីវិធានការការពារ និងហានិភ័យចំពោះខ្លួនឯង និងក្រុមគ្រួសារ។

- ចំពោះការប្រមូលទិន្នន័យអេដស៍ គឺគណៈកម្មាធិការអេដស៍ រាជធានី ខេត្ត ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ដោយធ្វើការជាមួយ *បណ្តាញប្រជាជនគន្លឹះ* (KP) ជាអ្នកប្រមូលទិន្នន័យនោះ ប៉ុន្តែបើខ្វះធនធានមនុស្សក្នុងការប្រមូលផ្តល់ជូន *អង្គការក្រៅរដ្ឋាភិបាល* (NGOs) *ឬអង្គការសង្គមស៊ីវិល* (CSOs) ធ្វើការក្នុងក្របខណ្ឌគណៈកម្មាធិការអេដស៍គ្រប់លំដាប់ថ្នាក់។
- ត្រូវជំរុញអនុវត្ត*គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (Fast Track City) ឱ្យបានទូលំទូលាយ។
- ការប្រជុំក្រុមប្រឹក្សាបច្ចេកទេស ត្រូវសង្កត់ធ្ងន់ ទី១) *គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (Fast Track City) ទី២) ខេត្តផ្សេងៗទៀតត្រូវរៀបចំរចនាសម្ព័ន្ធ ដោយពិនិត្យតាមដានលើដំណើរការអនុវត្តផែនការសកម្មភាព។
- ចំពោះ *មូលនិធិសកល (GF)* ត្រូវលើកទឹកចិត្តឱ្យជួយ *អង្គការក្រៅរដ្ឋាភិបាល* (NGOs) *ឬអង្គការសង្គមស៊ីវិល* (CSOs) ឱ្យមកជួយធ្វើការជាមួយគណៈកម្មាធិការអេដស៍គ្រប់លំដាប់ថ្នាក់។
- ត្រូវរៀបចំកម្មវិធីប្រជុំមួយនៅពាក់កណ្តាលខែមីនានេះ ដែល**ឯកឧត្តមទេសរដ្ឋមន្ត្រីនឹងអញ្ជើញចូលរួម** ដើម្បីធ្វើការវាយតម្លៃ ពីនីតិវិធីកំណត់លក្ខណសម្បត្តិនៃការផ្តល់រង្វាន់ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង និងរាជធានី ខេត្ត ដោយដាក់ពិន្ទុលើ ទី១) មានរបាយការណ៍ ទី២) របាយការណ៍ផ្តល់ជូនទាន់ពេលវេលា គ្រប់ជ្រុងជ្រោយ ចេះច្នៃប្រឌិត ទី៣) ស្ថាប័ន បានរៀបចំគណៈកម្មាធិការអេដស៍ និងបានប្រជុំគណៈកម្មាធិការអេដស៍ដែរឬទេ ទី៤) មានផែនការសកម្មភាពចំគោលដៅឬទេ ទី៥) បានលើកផែនការថវិកាឬទេ និងទី៦) មានសហការជាមួយអង្គការ សង្គមស៊ីវិលឬទេ។
- អគ្គលេខាធិការត្រូវប្រជុំជាមួយក្រសួងពាក់ព័ន្ធ ស្តីពីគោលការសុវត្ថិភាពសុខាភិបាលពេលវះកាត់ និងមិនមែនសុខាភិបាល ដូចជាសាក់លើខ្លួន។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យចំទិសដៅ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមយន្តការយុទ្ធសាស្ត្រនីមួយៗឱ្យកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០:៥៣នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ៣កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី

អ្នកធ្វើរបាយការណ៍

ស៊ុត_ថេងផាន់